# ទិដ្ឋាការចេញចូលមួយដង គោលបំណងទៅលេងបងប្អូន

ទិដ្ឋាការប្រភេទនេះគឺសម្រាប់សាមីជនដែលមានបំណងទៅលេងសាច់ញាតិ(ញាតិថ្នាក់ទី3 តាមខ្សែរផ្ទាល់ ឬសាច់ថ្លៃ) ដែលកំពុងស្នាក់នៅប្រទេសជប៉ុន។

| | | ឯកសារតម្រូវ | កំណត់ចំណាំ |
|---|---|---|---|
| ឯកសារត្រូវរៀបចំដោយសាមីជន | | | |
| ១ | ☐ | លិខិតឆ្លងដែន ច្បាប់ដើម | · មិនមានស្នាមប្រឡាក់ ឬការខូចខាត<br>· ត្រូវមាន២ទំព័រសម្រាប់បិទទិដ្ឋាការ |
| ២ | ☐ | ពាក្យស្នើសុំទិដ្ឋាការ *ច្បាប់ដើម*<br>*(បិទរូបថត១សន្លឹក)*<br><br>សេចក្តីពន្យល់អំពីការបំពេញពាក្យស្នើសុំ (ខ្មែរ) | · រូបថតបិទកាត (ថតថ្មីក្នុងរយៈពេល៦ខែ)<br>(បណ្តោយ: ៤.៥សង់ទីម៉ែត្រ x ទទឹង: ៣.៥សង់ទីម៉ែត្រ, ផ្ទៃពណ៌ស, រូបថតពណ៌ ឬសខ្មៅ)<br>· បំពេញពាក្យ "N/A" សម្រាប់សំណួរដែលមិនត្រូវនឹងលក្ខខណ្ឌរបស់អ្នក |
| ៣ | ☐ | ឯកសារបញ្ជាក់ពីទំនាក់ទំនង | · សំបុត្រកំណើត/អាពាហ៍ពិពាហ៍, សៀវភៅគ្រួសារ, លិខិតបញ្ជាក់ការចុះបញ្ជីគ្រួសារ“Kosekitohon”(ច្បាប់ដើម ឬចម្លង) ។ល។ |
| ៤ | ☐ | ឯកសារបញ្ជាក់លទ្ធភាពរ៉ាប់រងលើការចំណាយ | · ករណីសាមីជនជាអ្នកចំណាយដោយខ្លួនឯងសេចក្តីចម្លងតុល្យបញ្ជីគណនី Bank statements (ធ្វើបច្ចុប្បន្នភាពកំឡុងពេល៣ខែចុងក្រោយមកទល់នឹងថ្ងៃដាក់ពាក្យស្នើទិដ្ឋាការ)<br>មិនមែន BANK CONFIRMATION. |
| ឯកសារត្រូវរៀបចំដោយភាគីអញ្ជើញខាងជប៉ុន (ច្បាប់ដើម ឬចម្លង) | | | |
| ៥ | ☐ | លិខិតបញ្ជាក់មូលហេតុនៃការអញ្ជើញ | · មិនតម្រូវអោយមានត្រាទេ<br>· សូមពន្យល់ពី “គោលបំណងអញ្ជើញ” និង “ដើមហេតុនៃការអញ្ជើញ”អោយបានក្បោះក្បាយ។<br>· ករណីអញ្ជើញច្រើនជាងម្នាក់ សូមសរសេរ “ចំនួនបន្ថែមនៅលើលិខិតអញ្ជើញនេះ” និងភ្ជាប់ “បញ្ជីរាយនាមអ្នកដាក់ពាក្យសុំ”។ |
| ៦ | ☐ | លិខិតបញ្ជាក់ការចុះបញ្ជីគ្រួសារ(Kosekitohon) | · ករណីអ្នកអញ្ជើញ ឬគ្រួសារជាជនជាតិជប៉ុន (បញ្ជាក់ថ្មីៗក្នុងកំឡុងពេល៣ខែ) |

| | | | |
|---|---|---|---|
| ៧ | □ | លិខិតបញ្ជាក់ទីលំនៅ (Jyuminhyo) | · មានបញ្ជាក់ទាំងសមាជិកដែលរស់នៅជាមួយ (បញ្ជាក់ថ្មីៗក្នុងកំឡុងពេល៣ខែ) |
| ៨ | □ | តារាងស្នាក់នៅ | · សរសេរលម្អិតពីសកម្មភាពប្រចាំថ្ងៃ (ចាប់ពីថ្ងៃចូលរហូតដល់ចេញពីប្រទេសជប៉ុន)<br>· គម្រោងថ្ងៃចូលនិង ចេញពីជប៉ុន, ជើងហោះហើរដែលអ្នកគ្រោងជិះ, ឈ្មោះព្រលានសម្រាប់ហោះចូល និងចេញពីប្រទេសជប៉ុន។<br>· បំពេញពត៌មានកន្លែងស្នាក់/សណ្ឋាគារ (ឈ្មោះ, អាស័យដ្ឋាន, លេខទូរស័ព្ទ) |
| ៩ | □ | (ករណីអ្នកអញ្ជើញមិនមានសញ្ជាតិជប៉ុន) កាតស្នាក់នៅ និង លិខិតបញ្ជាក់ទីលំនៅ | · ច្បាប់ចម្លង(សងខាង)កាតស្នាក់នៅដែលមានសពុលភាពឬ លិខិតបញ្ជាក់ការស្នាក់នៅអចិន្ត្រៃយ៍ពិសេស<br>· ច្បាប់ចម្លងលិខិតបញ្ជាក់ទីលំនៅ"Jyuminhyo" (បញ្ជាក់ថ្មីៗក្នុងកំឡុងពេល៣ខែ)។ មានបង្ហាញពត៌មានទាំងអស់ដែលបានរាយបញ្ជី លើកលែងតែលេខសម្គាល់បុគ្គល"My Number" និងលេខកូដកំណត់ត្រាស្នាក់នៅ។ |
| ឯកសារត្រូវរៀបចំដោយភាគីធានានៅជប៉ុន(ករណីខាងជប៉ុនចេញថ្លៃចំណាយ) (ច្បាប់ដើម ឬចម្លង) | | | |
| ១០ | □ | លិខិតធានា | · មិនតម្រូវអោយមានត្រាទេ<br>· ករណីធានាច្រើនជាងម្នាក់ សូមសរសេរ "ចំនួនបន្ថែមនៅលើលិខិតធានានេះ" និងភ្ជាប់ "បញ្ជីរាយនាមអ្នកដាក់ពាក្យសុំ"។ |
| ១១ | □ | ឯកសារបញ្ជាក់លទ្ធភាពរ៉ាប់រងលើការចំណាយ | · ដាក់ឯកសារមួយក្នុងចំណោមឯកសារខាងក្រោម<br>-លិខិតបញ្ជាក់ប្រាក់ចំណូល/ការបង់ពន្ធចុងក្រោយបំផុត(ធ្វើដោយសាលាភូមិ ឃុំ សង្កាត់ ខណ្ឌ)។<br>-លិខិតបញ្ជាក់ការបង់ពន្ធ(ទម្រង់២, ធ្វើដោយការិយាល័យពន្ធដារ)។<br>- សេចក្តីចម្លងតុល្យបញ្ជីគណនី (ធ្វើដោយធនាគារ)<br>❖ យើងនឹងមិនទទួលឯកសារផ្សេងក្រៅពីឯកសារពាក់ព័ន្ធខាងលើ។ |